# ជីវប្រវត្តរបស់ អ៊ីម៉ាំ អាល់-ហ្ហាឌ្ឌី صلوات الله عليه والسلام



សៃយីដ្ ម៉ាស់ូឌី អាយ៉ាទុលឡ៍ហ៊ី
ស្ហាគីប បេនបេឌីវ៉ា

الهادی

-ព្រះនាមខ្លួន ៖ អាប៊ូ អាល់-ហ្កាសាន់ ។

-ព្រះនាមចំតើត ៖ អាល់ហ្វាឌី ។

-ព្រះនាមព្រះបិតា ៖ អ៊ីមុាំមូហ្កាំម៉ាដ់ អាល់-យ៉្ជាវ៉ាដ់ صلوات الله عليه والسلام ។

-ព្រះនាមមាតា ៖ ស៊ូម៉ាណាស្ហ់ ។

-ថ្ងៃប្រសូត ៖ ថ្ងៃទី ១៥ ស៊្ដុលហ្កីច្ជយ៉្ជាស្ហ់ ឆ្នាំ ២១២ សករាជ ហ្កិច្ជរ៉ោះត្ហ៍ ។

-ថ្ងៃទទួលទុក្ករកម្ម ៖ ថ្ងៃទី ៣ ខែរ៉យ៉្ជាប់ ឆ្នាំ ២៥៤ សករាជ ហ្កិច្ជរ៉ោះត្ហ៍ ។

-កន្លែងតម្កល់ព្រះចេតិយ ៖ សាម៉ារ៉អ៊ុំ ។

ٱلْحَمْدُ لِلَّهِ رَبِّ ٱلْعَٰلَمِينَ

16/08/2016

# បញ្ជីមាតិកា


កំណើត....4

សីលធម៌របស់អ៊ីមុាំ អាល់-ហ្វាឌី صلوات الله عليه والسلام....5

រឿងក្រចាប់ចិញ្ចៀន....6

ប្រឈមអាល់-មូតាវ៉ាក់គីល....9

ថ្លែងពាក្យពិតដាក់មុខបុគ្គលសាហាវយង់ឃ្នង....14

សកម្មភាពត្រចះត្រចង់ក្នុងប្រវត្តិសាស្ត្រ....19

ការផ្ទេរផ្ទេរជំណាក់អ៊ីមុាំ صلوات الله عليه والسلام....27

ស្ដេចខ័លិហ្វនិងកេរ្តិ៍ឈ្មោះអ៊ីមុាំ صلوات الله عليه والسلام....28

ទុក្ករកម្មរបស់អ៊ីមុាំ صلوات الله عليه والسلام....30

សិស្សរបស់អ៊ីមុាំ صلوات الله عليه والسلام....31

សម្រង់ព្រះវចនៈត្រចះត្រចង់....33

អត្តសញ្ញាណរបស់អ៊ីមុាំ صلوات الله عليه والسلام....33

# កំណើត

អ៊ីម៉ាំ អាលី អាល់-ហាឌី صلوات الله عليه والسلام (علي الهادي) ជាព្រះទាយាទស្របច្បាប់របស់ព្រះបិតា صلوات الله عليه والسلام ព្រះអង្គ អ៊ីម៉ាំ អាល់-យ៉ាវ៉ាដ់ صلوات الله عليه والسلام ។ ព្រះអង្គបានប្រសូតថ្ងៃទី ១៥ ស៊ុលហ៊ិជ្ជយ៉ាស្ហ់ ឆ្នាំ ២១២ សករាជ ហ៊ិជ្ជរ៉ោះត្ហ់នៅឯម៉ាឌីណាស្ហ់ ។ ព្រះអង្គជាអ៊ីម៉ាំអាស្ហ់លុល-បៃត៍ عليهم السلام ទី ១០ ។ អល់ឡោះហ្ហ់ عزّ وجلّ បានប្រគល់បេសកកម្មដ៏មហិមាមកលើព្រះអង្គ ឲ្យអភិរក្សព្រះសាសនាព្រះអង្គ عزّ وجلّ ឲ្យចាកផុតសេចក្តីវៀចវេរនិងការកែបំភ្លៃ ក្នុងសម័យមួយដែលលទ្ធិផ្តាច់ការនិយមរបស់រដ្ឋអំណាចអ៊ុប់បាស់នោះ ស្ទើរតែមានលក្ខណៈជាលទ្ធិយោធាទៅឯទ័ពទូរគីក៏កំពុងតែគំរាមខ្លាំងដែរ ។

មាតារបស់អ៊ីម៉ាំអាល់-ហាឌីមានសញ្ជាតិម៉ាគ្រិប (المغربية) មាននាមថាស៊ូម៉ាណាស្ហ់ (سمانة) ។ ដូច្នេះប្រជារាស្ត្រម៉ាគ្រិបបានទទួលរង្វាន់ជាលើកទីពីរ ព្រោះតែមានសេចក្តីស្មោះត្រង់ចំពោះអាស្ហ់លុល-បៃត៍ عليهم السلام ដោយបានចងសម្ពន្ធពង្សជាមួយអ៊ីម៉ាំសម័យកាល صلوات الله عليه والسلام ។

អ៊ីម៉ាំអាល់-ហាឌីបានទទួលព្រះបេសកកម្មអ៊ីម៉ាំម៉ាស្ហ់ ពេលព្រះអង្គមានព្រះជន្ម ៨ វស្សា ។ អាស្រ័យហេតុនេះ គំរោងការពន្លត់រស្មីអាស្ហ់លុល-បៃត៍ عليهم السلام របស់ពួកអ៊ុប់បាស់ ដោយដាក់ថ្នាំបំពុលអ៊ីម៉ាំអាល់-យ៉ាវ៉ាដ់ក្នុងព្រះ



អ៊ីម៉ាំបានសរសើរលោកច្រើកលើកច្រើនគ្រា ថាលោកអ្នកប្រាជ្ញមួយរូបដែលអាចឆ្លើយតបសំណួរប្រជារាស្ត្រមូស្លីមនៃខេត្តឃូរ៉សានបានគ្រប់សំណួរ ។

## សម្រង់ព្រះវចនៈត្រចះត្រចង់

– អ្នកណាស្តាប់បង្គាប់ព្រះទ្រង់អ្នកបង្កើត عزّ وجلّ អ្នកនោះមិនត្រូវយកចិត្តទុកដាក់នឹងកំហឹងសត្វលោកឡើយ ។

– ចូរប្រយ័តបុគ្គលណាដែលបាត់បង់សេចក្តីគោរពខ្លួនឯង ។

– អ្នកណាគាប់ចិត្តខ្លួនឯង អ្នកនោះត្រូវតែមានអ្នកប្រឆាំង ។

– អ្នកធ្វើល្អប្រសើរជាងអំពើល្អ ។ រីឯអ្នកធ្វើអាក្រក់អប្រិយលើសអំពើអាក្រក់ ។

– ការស្តីបន្ទោសប្រសើរជាងគំនុំគុំកួន ។

– អ៊ីម៉ាំអាល់-ហាឌីមានវចនៈជាមួយអាល់-មូតាវ៉ាក់គីលថា៖ «ចូរកុំស្វែងរកភក្តីភាពពីបុគ្គលដែលខ្លួនបានក្បត់ហើយនោះ ។»

## អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام

-ព្រះនាម ៖ អាលី ។

លាក់អស់រយៈពេលដ៏យូរនៅក្នុងស្រុករៃ (ري ទេហេរ៉ង់ខាងត្បូង) ហើយលោកទទួលអនិច្ចកម្មនៅទីនេះ ។ ចេតិយរបស់លោកគង់នៅរហូតដល់សព្វថ្ងៃ ហើយជាស្ថានទីមួយដែលអ្នកមានជំនឿរាប់ពាន់នាក់សំដៅទៅទស្សនារៀងរាល់ឆ្នាំ ។

**២-អាល់-ហាសាន់ ប៊ិន សាអ៊ីដ អាល់-អាស់វ៉ាស៊ី** (حسن بن سعيد الاهوازى)**។** លោកជាសិស្សម្នាក់របស់អ៊ីម៉ាំអាររីដ្ឋ صلوات الله عليه والسلام ហើយជាសិស្សរបស់អ៊ីម៉ាំអាល់-យ៉ាវ៉ាដ់ صلوات الله عليه والسلام ក្រោយមកជាសិស្សរបស់អ៊ីម៉ាំអាល់-ហាឌី ។ លោកបានរស់នៅស្រុកគូហ្វាស់ នៅបាកុំដាដ់ ទីបំផុតនៅស្រុកគុមអស់មួយជីវិតលោក ។ លោកជាអ្នកប្រាជ្ញល្បីមួយរូបដែលបានបន្សល់ទុកនូវស្នាដៃចំនួន ៣០ សាត្រាស្តីអំពីវិន័យនានារបស់សាសនាអ៊ីស្លាម ។

**៣-អាល់-ហ្វាដល់ ប៊ិន ស្វាស៊ាន** (الفضل بن شاذان)**។** លោកជាសិស្សរបស់អ៊ីម៉ាំអាល់-ហាឌី ក្រោយមកជាសិស្សរបស់បុត្រ صلوات الله عليه والسلام ព្រះអង្គ អ៊ីម៉ាំហាសាន់អាល់-អាស់ការី صلوات الله عليه والسلام ។ លោកកើតនៅឯស្រុកនីស្វាប៊ូរ ខេត្តយូរ៉សាន ។



ជន្ម ២៥ វស្សានោះត្រូវវិនាស ។ ពិតណាស់ អាស្រ័យលើបទឧក្រិដ្ឋនេះ ពួកអាប់បាស់មានបំណងកាត់ផ្តាច់ រាជវង្សអ៊ីម៉ាំស្របច្បាប់អាស់លុល-បៃត់ عليهم السلام ដោយស្មានថា ក្នុងព្រះជន្មនេះ អ៊ីម៉ាំអាល់-យ៉ាវ៉ាដ់មិនអាចផ្សព្វផ្សាយមូលហេតុព្រះអង្គដល់បណ្តាអ្នកស្វែងរកការពិតបានទេ ។ តែបទឧក្រិដ្ឋនេះកាន់តែធ្វើឲ្យអ្នកគាំទ្រអាស់លុល-បៃត់ عليهم السلام ស្មោះត្រង់ឡើង ហើយកាន់តែធ្វើឲ្យព្រះទាយាទរបស់ព្រះសាស្តាមានប្រិយភាពឡើង ដោយមិនរើសអើងអាយុព្រះអង្គឡើយ ។

អ៊ីម៉ាំអាស់លុល-បៃត់ عليهم السلام ទី ១០ មានព្រះនាមច្រើនដែលឆ្លុះបញ្ចាំងឲ្យឃើញនូវសម្បត្តិសីលធម៌ព្រះអង្គ ។ តែគេតែងតែហៅព្រះអង្គថា “អាល់-ហាឌី” (الهادي មានន័យថា អ្នកដឹកនាំទៅកាន់មាគ៌ាល្អ) និង “អាន់-ណាគី” (النقي មានន័យថា បរិសុទ្ធ ជ្រះថ្លា)

## សីលធម៌របស់អ៊ីម៉ាំ អាល់-ហាឌី صلوات الله عليه والسلام

គេតែងតែឮល្បីថាអ៊ីម៉ាំអាល់-ហាឌីជាបុរសកាន់វត្តប្រតិបត្តិល្អ ជាបុរសសុភាពរាបសានិងមានចិត្តទូលាយ ជាគំរូដ៏ប្រសើរបំផុត ។ ព្រះអង្គរស់នៅក្នុងបន្ទប់ដ៏សាមញ្ញមួយ គ្មានការតុបតែង គ្មានគ្រឿងសង្ហារិមទេ ។ ព្រះអង្គ

ប្រើពេលមួយប៉ែកធំក្នុងការសូត្រព្រះគម្ពីរគួរអាន ។ ពេលព្រះអង្គមានថវិកា ព្រះអង្គចែកឲ្យទៅជនក្រីក្រនិងតោកយ៉ាកមុស្លីម ។

ស្តេចខ័លិហ្វឈ្មោះ អាល់-មូតាវ៉ាក់គីល (المتوكل) បានធ្លាក់ខ្លួនឈឺ គ្រូពេទ្យទាំងអស់ក្នុងសម័យនោះគិតថាជម្ងឺនេះមិនអាចព្យាបាលជាទេ ។ តែមាតារបស់ស្តេចខ័លិហ្វមានគំនិតឈ្លាសវៃ បានពិភាក្សាជាមួយអ៊ីមុាំអាល់-ហាឌី បានចាត់បញ្ជូនមន្ត្រីរបស់ស្តេចខ័លិហ្វទៅសូមយោបល់ពីព្រះអង្គ ។ អ៊ីមុាំអាល់-ហាឌីបានដាក់បញ្ញត្តិវិធីព្យាបាលមួយដែលមានប្រសិទ្ធិភាព ស្តេចខ័លិហ្វក៏បានជាសះស្បើយ ។ មាតារបស់ស្តេចខ័លិហ្វរីករាយណាស់ បានផ្ញើប្រាក់មួយពាន់ឌីណារឲ្យអ៊ីមុាំអាល់-ហាឌី អ៊ីមុាំអាល់-ហាឌីបញ្ជាប់យកប្រាក់នោះទៅចែកឲ្យជនក្រីក្រតោកយ៉ាកលំបាកក្រៃក្រាស់។

## រឿងក្រចាប់ចិញ្ចៀន

អ៊ីមុាំជាសេនារបស់អល់ឡោះហ៍ عزّ وجل នៅលើផែនដី ។ អ៊ីមុាំមានឋានៈពិសេសសម្រាប់អល់ឡោះហ៍ عزّ وجل ឋានៈពិសេសនេះជាជម្រកតែមួយគត់និងចុងក្រោយបំផុតសម្រាប់សត្វលោកគ្រប់រូបដែលមានភ័យអាសន្ន ។

អ៊ីមុាំអាល់-ហាឌីរស់នៅក្នុងសម័យមួយ ដែលត្រកូលអាប់បាស់បានក្លាយ



សម្រេចចិត្តកម្ចាត់អ៊ីមុាំអាល់-ហាឌី បានបញ្ជាឲ្យភ្នាក់ងាររបស់ខ្លួនដាក់ថ្នាំបំពុលព្រះអង្គ ។

អ៊ីមុាំបានចាកចោលលោកនេះក្នុងព្រះជន្ម ៤២ ព្រះវស្សា ក្នុងឆ្នាំ ២៥៤ សករាជហ៊ីជរ៉ោះត៍ ។ ព្រះរាជសពព្រះអង្គត្រូវបញ្ចុះនៅឯស្រុកសាម៉ារ៉អ៍ ព្រះចេតិយព្រះអង្គនៅរហូតមកដល់សព្វថ្ងៃ ហើយជាស្ថានទីមួយដែលអ្នកមានជំនឿរាប់ពាន់នាក់ចូលចិត្តសំដៅទៅទស្សនារៀងរាល់ឆ្នាំ ។

## សិស្សរបស់អ៊ីមុាំ صلوات الله عليه والسلام

ទោះជាអ៊ីមុាំអាល់-ហាឌីត្រូវគេរឹតត្បិតក៏ដោយ ជំនួយរបស់ព្រះអង្គ តាមរយៈសិស្សភក្តីរបស់ព្រះអង្គ បានជះឥទ្ធិពលទៅលើវិស័យវិទ្យាសាស្ត្រក្នុងសម័យកាលព្រះអង្គ ។ សិស្សល្បីៗរបស់អ៊ីមុាំអាល់-ហាឌីមាន៖

**១-អាប់ឌុលអាស៊ីម អាល់-ហាសានី** (عبد العظيم الحسني)។ លោកជាកូនចៅរបស់អ៊ីមុាំអាល់-ហាសាន់ صلوات الله عليه والسلام ជាសិស្សភក្តីម្នាក់ និងជាសាវកម្នាក់របស់អ៊ីមុាំអាល់-ហាឌី ។ ព្រះអង្គបានសរសើរលោកច្រើនលើក ច្រើនគ្រា ។ អាប់ឌុលអាស៊ីម អាល់-ហាសានីជាអ្នកប្រឆាំងរបបអាប់បាស់យ៉ាងខ្លាំង ។ ដោយសារតែលោកត្រូវពួកនគរបាលតាមចាប់ខ្លួនលោក លោកបានរស់នៅដោយលួច

ថយក្រោយក្រាក មិនប៉ះពាល់ទេ ។ ស្តេចខ៏លិហ្វធ្វើជាសូមឲ្យអ៊ីម៉ាំសូត្រកំណាព្យឲ្យស្តាប់ ។ រក្សាឥរិយាបថស្ងាត់ស្ងៀម មិនតក់ស្លុត អ៊ីម៉ាំបានតបបុរសកំណាចថាព្រះអង្គមិនចូលចិត្តកំណាព្យទេ តែឥតប្រយោជន៍ទេ ។ ស្តេចខ៏លិហ្វស្រវឹងរំអុកទារ ទាល់តែអ៊ីម៉ាំសូត្រកំណាព្យវែងមួយឲ្យស្តាប់ ធ្វើឲ្យស្តេចខ៏លិហ្វស្វាងពីអាការស្រវឹង ។ អ៊ីម៉ាំបានសូត្រកំណាព្យវែងមួយដែលមានអត្ថន័យដាស់តឿន អារម្មណ៍ស្តេចខ៏លិហ្វថានៅទីបំផុតខ្លួននឹងបានចូលផ្នូរ នៅក្នុងផ្នូរនោះខ្លួននឹងមិនបានទទួលអ្វីទេក្រៅពីលទ្ធផលនៃទង្វើរបស់ខ្លួន ។ ទៅជាភ័យខ្លាចពេក ស្តេចខ៏លិហ្វក៏បានយំយែក ហើយបានជូនដំណើរអ៊ីម៉ាំអាល់-ហាឌីដល់មាត់ទ្វារវាំង ។

## ទុក្ករកម្មរបស់អ៊ីម៉ាំ صلوات الله عليه والسلام

នៅទីបំផុត អាល់-មូតាវ៉ាក់គីលត្រូវគេលួចសម្លាប់ ៦ ខែក្រោយមក ។ អ្នកស្នងអាល់-មូតាវ៉ាក់គីល ឈ្មោះអាល់-មុនតាស្សៀរ (المنتصر) ត្រូវគេលួចសម្លាប់ដែរ ។ ផែនការសម្ងាត់ក្នុងរាជវាំងបានតែងតាំងអាល់-មុសតាអ៊ីន (المستعين) លើបល្ល័ង្ក ។ ស្តេចខ៏លិហ្វរូបនេះបានកាន់អំណាចបីឆ្នាំ បន្ទាប់មក អាល់-មុអ៊ុតាស់ (المعتز) បានឡើងកាន់អំណាច ។ អាល់-មុអ៊ុតាស់បាន



ទៅជាអំណាចផ្តាច់ការយោធា ដែលគាបសង្កត់ឥតអាណិតអាសូរអ្នកប្រឆាំងគ្រប់រូប ។ ដូច្នេះទំនាក់ទំនងរបស់អ្នកគាំទ្រអាស់ហ្លុល-បៃត៍ عليهم السلام ជាមួយអ៊ីម៉ាំពួកគេត្រូវថយចុះ ។ ស្នាដៃនិងអព្ភូតហេតុនានារបស់អ៊ីម៉ាំដែលបានកើតមានឡើងអាស្រ័យបុណ្យបារមីព្រះអង្គនោះ ត្រូវរាជអំណាចត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ។ ដូច្នេះហើយបានជាព្រឹត្តិការណ៍នានាពាក់ព័ន្ធនឹងជីវិតព្រះអង្គបានលេចឮមកដល់យើងតិចណាស់ ។ ព្រឹត្តិការណ៍មួយចំនួនធំដែលបានគេចផុតពីប្រព័ន្ធត្រួតពិនិត្យនោះ គឺព្រឹត្តិការណ៍ដែលពួកមន្ត្រីភ្នាក់ងាររបស់រាជអំណាចផ្ទាល់តែម្តងបានតំណាល ឬពួកអ្នកបម្រើតែម្តង ។

ឧទាហរណ៍ រឿងចិញ្ចៀនរបស់ស្តេចខ៏លិហ្វជាភ័ស្តុតាងបង្ហាញឲ្យឃើញនូវតម្លៃនិងឋានៈវិសាមញ្ញរបស់អ៊ីម៉ាំអាល់-ហាឌី ។ អ្នកប្រវត្តិសាស្ត្របានធ្វើសេចក្តីរាយការណ៍ថា ស្តេចខ៏លិហ្វបានចាត់ជាងមាសម្នាក់ឲ្យឆ្លាក់ក្រចាប់ចិញ្ចៀនដ៏មានតម្លៃមួយសម្រាប់ស្តេចខ៏លិហ្វរូបនេះផ្ទាល់តែម្តង ។ តែក្រចាប់ចិញ្ចៀនបាក់ក្នុងពេលដែលជាងឆ្លាក់ ។ ជាងមាសភ័យណាស់ គាត់ខ្លាចតែមានគ្រោះថ្នាក់ ។ សំណាងល្អ ជាងមាសមានគំនិតវៃ បានទៅរកអ៊ីម៉ាំអាល់-ហាឌី ព្រះអង្គបានបួងសួងអល់ឡោះហ៍ عزّ وجلّ ឲ្យគាត់ ធ្វើឲ្យគាត់មាន







## ស្តេចខ៏លិហ្វនិងកេរ្តិ៍ឈ្មោះអ៊ីមុាំ صلوات الله عليه والسلام

ស្តេចខ៏លិហ្វមិនដឹងនឹងធ្វើយ៉ាងឲ្យអាប់កេរ្តិ៍ឈ្មោះអ៊ីមុាំ ដែលកំពុងតែល្បីរន្ទឺពេញពិភពលោក ។ ថ្ងៃមួយ ស្តេចខ៏លិហ្វគិតថា បើកោះហៅប្អូន (ប្អូបង) របស់អ៊ីមុាំអាល់-ហាឌី ឈ្មោះមូសា មកឯរាជវាំង ប្រាកដជាអាចបន្ទុចកេរ្តិ៍ឈ្មោះអ៊ីមុាំបាន ។ ដូច្នេះស្តេចខ៏លិហ្វក៏បានកោះហៅមូសាដោយសន្យាឲ្យរង្វាន់ច្រើន ។

ទោះជាអ៊ីមុាំអាល់-ហាឌីបានឲ្យយោបល់ហើយក៏ដោយ មូសាជំពាក់ចិត្តទៅលើរង្វាន់របស់ស្តេចខ៏លិហ្វ ។ មូសាក៏បានទៅជួបស្តេចខ៏លិហ្វ ដោយផ្តាច់សន្តសម្ព័ន្ធរវាងលោកនឹងបង (ប្អូន) លោក គឺអ៊ីមុាំសម័យកាល ។ តែយោលតាមគេថា លោកមិនទាំងបានចូលទៅក្នុងរាជវាំងផង ។ ចំណែកអ៊ីមុាំវិញក៏បានរួចខ្លួន ។

អ្វីដែលធ្វើឲ្យស្តេចខ៏លិហ្វត្រកូលអុាប់បាស់ទាស់ចិត្ត គឺកេរ្តិ៍ឈ្មោះអ៊ីមុាំអាល់-ហាឌី ។ អាល់-មូតាវ៉ាក់គីលស្វែងរកមធ្យោបាយគ្រប់យ៉ាងដើម្បីបន្ទុចកេរ្តិ៍ឈ្មោះព្រះអង្គ ។ យប់មួយ ខណៈដែលស្រវឹងខ្លាំង អាល់-មូតាវ៉ាក់គីលបានបញ្ជាឲ្យនាំអ៊ីមុាំអាល់-ហាឌីមកជួបភ្លាម ។ មិនយូរប៉ុន្មានគេបាននាំអ៊ីមុាំមកជួបស្តេចខ៏លិហ្វ ។ បុរសកំណាចបានហុចកែវស្រាឲ្យអ៊ីមុាំ



សេចក្តីទុកចិត្តអំណឹះតទៅ ។ ស្អែកឡើង ជាងមាសមានកិត្តិយសបានឃើញហេតុអស្ចារ្យគឺ៖ ភ្នាក់ងាររបស់ស្តេចខ៏លិហ្វបានមកសូមឲ្យជាងមាសពុះចែកក្រចាប់ជាពីរដើម្បីធ្វើចិញ្ចៀនពីរ ។ ជាងមាសស្ទើរតែមិនជឿអ្វីដែលខ្លួនបានឮនោះទេ គាត់ខំទប់សេចក្តីត្រេកអរមិនឲ្យផ្ទុះចេញមកក្រៅ ។ គាត់ដឹងខ្លួនថាអល់ឡោះហ៍ عزوجل បានប្រោសប្រណីគាត់ តាមរយៈព្រះអគ្គសេនារបស់ព្រះអង្គ عزوجل នៅលើផែនដី គឺអ៊ីមុាំសម័យកាល អុាលី អាល់-ហាឌី صلوات الله عليه والسلام ។

## ប្រឈមអាល់-មូតាវ៉ាក់គីល

បន្ទាប់ពីស្តេចខ៏លិហ្វត្រកូលអុាប់បាស់ អាល់-មុអ៍តាស៊ីម (المعتصم) បានស្លាប់ទៅ កូនប្រុសរបស់ស្តេចខ៏លិហ្វរូបនេះ ឈ្មោះ អាល់-វ៉ាស៊ីក្វ (الواثق)បានឡើងសោយរាជ្យអស់ ៥ ឆ្នាំ ៩ ខែ ។ បន្ទាប់ពីនេះ អាល់-មូតាវ៉ាក់គីល បានឡើងសោយរាជ្យជាបន្ត ដើម្បីនឹងធ្វើឲ្យដំណើរការវិនាសទូទៅកាន់តែលឿនទៅមុខទៀត គឺដំណើរការវិនាសទូទៅដែលស្តេចមុនៗបានចាប់ផ្តើមបង្កជាស្រេចមកហើយ ។ ឈានដល់ដំណាក់ការនេះ ក្នុងប្រវត្តិអាណាចក្រអុាប់បាស់ ពួកស្តេចខ៏លិហ្វត្រកូលអុាប់បាស់មិនទុកចិត្តពួកអារ៉ាប់ ពួកពែរ្ស៍និងប្រតិភូរបស់ពួកនេះទេ រហូតដល់មិនទុកចិត្តពួកមេទ័ពអាជីពដែលមាន

ក្រសែលោហិតទូរគី ។

ចំណុចដែលសម្គាល់ឲ្យដឹងថាស្តេចខ័លិហ្វត្រកូលអុាប់បាស់ អាល់-មូតាវ៉ាក់គីលប្លែកពីគេគឺ ស្តេចខ័លិហ្វរូបនេះគុំកួនអាស្ហុល-បៃត៍ عليهم السلام ឥតអាណិតអាសូរឡើយ ជាពិសេសគុំកួនអ៊ីមុាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام និងអ៊ីមុាំអុាលី صلوات الله عليه والسلام ។ អំពើថោកទាបបំផុតដែលបុគ្គលរូបនេះបានប្រព្រឹត្តនោះគឺ ព្យាយាមបំផ្លិចបំផ្លាញបំបាត់ដានព្រះចេតិយ ដែលមុស្លីមបានសាងនៅលើផ្នូរអ៊ីមុាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ដោយបង្វែរទឹកចេញពីស្ទឹងអាល់-ហ្វូរ៉ាតមកពន្លិចសំណង់ពិសិដ្ឋការបាឡាអ៊ុំ ។ អាល់-មូតាវ៉ាក់គីលមិនត្រឹមតែប្រព្រឹត្តបទប្រមាថពិសិដ្ឋវត្ថុប៉ុណ្ណោះទេ ស្តេចខ័លិហ្វរូបនេះបានបង្កើតច្បាប់មួយដែលហាមទៅធ្វើទស្សនកិច្ចព្រះចេតិយអ៊ីមុាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ហើយបានដាក់បញ្ជាឲ្យពេជ្ឈឃាដប្រហារជីវិតអ្នកណា ដែលហ៊ានទៅកាន់ការបាឡាអ៊ុំដើម្បីធ្វើទស្សនកិច្ចព្រះចេតិយអ៊ីមុាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ។

អំពើហិង្សាមកលើអវិរុទ្ធបុគ្គលអាស្ហុល-បៃត៍ صلوات الله عليه والسلام និងអំពើឈ្លានពានទៅលើព្រះចេតិយអ៊ីមុាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام របស់ស្តេចខ័លិហ្វត្រកូលអុាប់បាស់រូបនេះកាន់តែធ្វើឲ្យសំណាក់មុស្លីម ស្រឡាញ់ដោយស្មោះព្រះ



ព្រះអង្គដូចសុនកស្រឡាញ់ម្ចាស់ មិនបង្ហាញនូវអាការគោចសាហាវទេ ។ បន្ទាប់មកអ៊ីមុាំបានចេញពីអាង ស្តេចខ័លិហ្វចាកចេញទាំងអាម៉ាស់មុខកាន់តែគុំកួនខ្លាំងឡើង ។

## ការឆែកឆេរដំណាក់អ៊ីមុាំ صلوات الله عليه والسلام

ពេលដឹងថា អ៊ីមុាំអាល់-ហ្វាឌីកាន់តែបានទទួលប្រិយភាពពីសំណាក់ប្រជារាស្ត្រមុស្លីម អាល់-មូតាវ៉ាក់គីលមិនជឿទេថាអ៊ីមុាំនឹងមិនទាញយកប្រិយភាពនេះមករំលំរបបអុាប់បាស់ទេ ។ ពួកយកគាប់យកគួរបុគ្គលកាន់អំណាចផ្តាច់ការត្រកូលអុាប់បាស់ធ្វើសេចក្តីរាយការណ៍ថា អ៊ីមុាំអាល់-ហ្វាឌីកំពុងតែរៀបចុះធ្វើបដិវត្តន៍ប្រដាប់អាវុធ ថាព្រះអង្គលាក់អាវុធនិងប្រាក់យ៉ាងច្រើនទុកក្នុងដំណាក់ព្រះអង្គ ។ អាល់-មូតាវ៉ាក់គីលបានបញ្ជាឲ្យឆែកឆេរដំណាក់អ៊ីម៉ាអាល់-ហ្វាឌីភ្លាម ។ តែការឆែកឆេរនេះមិនបានផលទេ អគិបាលរាជវាំង ឈ្មោះសាអ៊ីដ ដែលជាអ្នកដឹកនាំការឆែកឆេរនេះ សូមទោសអ៊ីមុាំៗបានតបវិញដោយអាយ៉ាត់គួរអានមួយ ។ រួចហើយពួកភ្នាក់ងាររបស់ស្តេចខ័លិហ្វបានចាកចេញទុកឲ្យអ៊ីមុាំធ្វើនមស្ការតទៅទៀត នមស្ការដែលពួកគេបានធ្វើឲ្យអាក់ខាន ។







ទាយាទអាស្វ់លុល–បៃត៍ صلوات الله عليه والسلام អ៊ីមុាំអ៊ាលី អាល់–ហ្វាឌី صلوات الله عليه والسلام ។

ពិតណាស់ នៅឯម៉ាឌីណាស្វ់ អ៊ីមុាំអាល់–ហ្វាឌីបានក្លាយទៅជាគំរូពិតៗ សម្រាប់មុស្លីមទាំងអស់ និងសម្រាប់ជនមួយចំនួនផងដែរដែលសព្វមួយដង មិនដែលអើពើនឹងទុក្ខវេទនា ដែលក្រុមគ្រួសាររបស់ណាប៊ី صلى الله عليه وآله وسلم បានទទួលរង នោះទេ ។

កិត្តិសព្ទល្បីរន្ទឺនេះធ្វើឲ្យអាល់–មូតាវ៉ាក់គីលទាស់ចិត្តអនេក ។ ស្ដេចខ៏លិហ្វអសទ្ធារូបនេះ ដែលប្រកបដោយគំនុំ បានបញ្ចេញប្រតិកម្មភ្លាមដើម្បីកម្ចាត់អ៊ីមុាំ ។ ព្រោះតែខ្លាចមិនអាចគ្រប់គ្រងប្រជារាស្ត្រមុស្លីមបះបោរបាន អំណាចអ៊ាប់បាស់បានចាត់វិធានការ សាកល្បងមើលប្រតិកម្មរបស់មហាជនជាមុនសិន ។ ស្ដេចខ៏លិហ្វរូបនេះបានចាត់ឲ្យមេបញ្ជាការម្នាក់ទៅផ្សាយដំណឹងក្នុងសំណាក់មុស្លីមថាគេនឹងចាប់ខ្លួនអ៊ីមុាំ ។ ដំណឹងនេះបានលេចឮក្នុងចំណោមប្រជារាស្ត្រម៉ាឌីណាស្វ់ បណ្ដាលឲ្យសំណាក់អភិជននគរម៉ាឌីណាស្វ់រំជើបរំជួល នាំគ្នាទៅជួបបេសកជនរបស់ស្ដេចខ៏លិហ្វ សូមឲ្យភ្នាក់ងាររូបនេះអធិប្បាយបំភ្លឺអំពីបេសកកម្មពិតរបស់ខ្លួន ។ លុះបានឃើញសំណាក់អភិជននគរម៉ាឌីណាស្វ់មានសេចក្ដីប្ដេជ្ញាចិត្ត និងខ្លាចមានការ



ថ្ងៃមួយ នារីម្នាក់បានអះអាងថាខ្លួនគឺអភិនារីស៊ៃណាប់ រាជបុត្រីរបស់អ៊ីមុាំអ៊ាលី عز وجل ហើយខ្លួនបានត្រឡប់ជាមានយុវវ័យវិញហាសិបឆ្នាំម្ដង ។ ស្ដេចខ៏លិហ្វនិងភ្នាក់ងារមិនដឹងធ្វើអ្វីចំពោះសេចក្ដីអះអាងរបស់នារីនេះ ។ នៅទីបំផុត មានតែអ៊ីមុាំអាល់–ហ្វាឌីទេដែលអាចជួយដោះស្រាយបញ្ហាពួកគេបាន ។ អ៊ីមុាំអាល់–ហ្វាឌីបានឲ្យប្រាប់នារីនោះថារាជបុត្ររាជនត្តារបស់ព្រះសាស្ដាសុទ្ធតែមានគុណសម្បត្តិមួយគឺៈ សត្វសាហាវមិនប៉ះពាល់រាជបុត្ររាជនត្តាទាំងនោះជាដាច់ខាត ។ ដូច្នេះ ដើម្បីឲ្យដឹងថាអ៊ីមុាំនិយាយពិត នារីនោះត្រូវប្រឈមនឹងសត្វសាហាវនៅក្នុងទ្រុងមួយ ដោយដាក់នារីនេះនិងសត្វសាហាវជាមួយគ្នា ។ នារីរូបនោះបានសារភាពថាខ្លួនបាននិយាយកុហក ។ តែមូតា–វ៉ាក់គីល ស្ដេចកំណាច ធ្វៀតយកឱកាសនេះបំបាក់មុខអ៊ីមុាំអាល់–ហ្វាឌី ដោយសូមឲ្យព្រះអង្គប្រឈមនឹងសត្វសាហាវដោយត្រង់ៗតែម្ដងក្នុងកាលៈទេសៈដូចនារីកុហកនោះដែរ ។ តែអល់ឡោះហ៍ عز وجل ទ្រង់ញាណបុគ្គលដែលអាចទទួលព្រះរាជសារព្រះអង្គ عز وجل បាន ។ អ៊ីមុាំអាល់–ហ្វាឌីបានប្រឈមនឹងសត្វសាហាវក្នុងអាងធំមួយ នៅចំពោះមុខមហាជនស្រឡាំងកាំង ។ សត្វសាហាវទាំងនេះចោមព្រះអង្គយ៉ាងស្ងៀមស្ងាត់ ទទួល

បៀតបៀន បុគ្គលរូបនេះបានសច្ចាចំពោះអល់ឡោះហ៊ុ عزّ وجلّ ថានឹងដាក់ទានចំនួនប្រាក់ច្រើនខ្ទីណារ ។ ជាពីដម្បីវិញ ជនជំនិតរបស់ស្តេចខ័លិហ្វមិនស្របមតិគ្នាអំពីពាក្យថា "ច្រើន" ហើយមិនដឹងថានឹងអាចជួយដោះខ្លួនព្រះចៅរបស់ពួកគេ ឬជួយបំពេញតាមពាក្យសច្ចានោះដោយវិធីណាទេ ។ ពួកគេក៏បានទៅសូមយោបល់ពីអ៊ីមុាំអាល់-ហ្វាឌី ។ ព្រះអង្គបានប្រាប់ពួកគេថា ត្រូវបកស្រាយពាក្យថា "ច្រើន" នោះដោយលេខ ៨០ ។ ពេលអាល់-មូតាវ៉ាក់គីលសួរព្រះអង្គ صلوات الله عليه والسلام អំពីមូលហេតុនៃលេខនេះ អ៊ីមុាំបានរំលឹកថាអល់ឡោះហ៊ុ عزّ وجلّ មានព្រះបន្ទូលនោះក្នុងគម្ពីរអានថា៖ «អល់ឡោះហ៊ុបានជួយសង្គ្រោះពួកអ្នករួចមកហើយនាច្រើនកន្លែង ។ (ស៊ី.៩, អា.២៥)» ហើយពេលរាប់ចំនួនសមរភូមិមុស្លីម ឃើញមានចំនួន ៨០ ។

អាល់-មូតាវ៉ាក់គីលបានឃើញសេចក្តីឆ្លាតវៃ និងសព្វញ្ញុតាភាពច្រើនទៀតរបស់អ៊ីមុាំអាល់-ហ្វាឌី ។ ក៏ប៉ុន្តែទិដ្ឋភាពសត្វសាហាវជាទិដ្ឋភាពដែលធ្វើឲ្យរំភើបជាងគេ ។ បើមាននូវស្លាកស្នាមជំនឿនៅក្នុងបេះដូងបុគ្គលសាហាវយង់ឃ្នងត្រកូលអាប់បាស់នេះមែន ស្តេចខ័លិហ្វរូបនេះប្រាកដជាដកស្រង់បាននូវសេចក្តីសន្និដ្ឋានល្អសម្រាប់ខ្លួនឯងនិងសម្រាប់បរិវាររបស់ខ្លួន ។





បះបោរក្នុងពេលដែលអំណាចពួកអាប់បាស់កំពុងតែមិនមាំមួននោះ ភ្នាក់ងាររបស់ស្តេចខ៏លិហ្វ បានធ្វើឲ្យប្រែជាព្រ្តួនគរម៉ាឌីណាស្ទំមានសេចក្តីទុកចិត្តឡើងវិញដោយប្រាប់ឲ្យដឹងគោលបំណងពិតរបស់ខ្លួន ហើយបានសន្យាពួកគេថាមិនមានបំណងអាក្រក់ចំពោះអ៊ីម៉ាំអាល់-ហាឌីទេ ។ បេសកជនរូបនេះបានអះអាងយ៉ាងព្រហើនថា ស្តេចខ៏លិហ្វត្រកូលអាប់បាស់គោរពនិងលើកតម្កើងព្រះរាជវង្សអង្គនេះយ៉ាងសក្តិសមតាមបុណ្យសក្តិព្រះអង្គ ហើយស្តេចខ៏លិហ្វចង់ទទួលព្រះអង្គទៅកាន់រាជធានីរបស់ខ្លួន ។ ដូច្នេះហើយបានជាអ៊ីម៉ាំអាល់-ហាឌីចាំបាច់ត្រូវចាកចេញពីនគរម៉ាឌីណាស្ទំ ទៅនៅក្បែរស្តេចខ៏លិហ្វត្រកូលអាប់បាស់ ។ ការពិត នេះជាការឃុំខ្លួនឲ្យនៅតែក្នុងផ្ទះដែលត្រូវគេឃ្លាំមើល ហើយត្រូវកាត់ផ្តាច់ទំនាក់ទំនងពីបណ្តាសាវកព្រះអង្គ ។

## ថ្លែងពាក្យពិតដាក់មុខបុគ្គលសាហាវយង់ឃ្នង

ការដាក់កម្រិតមកលើអ៊ីម៉ាំអាល់-ហាឌី ដោយស្តេចខ៏លិហ្វត្រកូលអាប់បាស់ មិនមានប្រសិទ្ធិភាពជាងការដាក់កម្រិតលើព្រះបុព្វការីរបស់អ៊ីម៉ាំ ដោយស្តេចខ៏លិហ្វមុនៗអាល់-មូតាវ៉ាក់គីលនោះទេ ។ ដូច្នេះព្រះបន្ទូលអល់ឡោះហ៍ عزّ وجلّ បានជ្រួតជ្រាប ទៅដល់ក្រអៅបេះដូងទាំងឡាយដោយ



អារម្មន៍ភ្នាក់ងារនេះ ។ ព្រះអង្គបានប្រាប់ភ្នាក់ងារនេះថា៖ «ដំបូងលោកមិនស្តាប់យោបល់ខ្ញុំទេ ក្រោយមកលោកគិតថាខ្ញុំជាគ្រូមន្តអាគម ។ ចូរលោកដឹងថាមិនមែនអ្វីទាំងនេះទេ ។ ខ្ញុំស្គាល់រាលនេះ ខ្ញុំស្គាល់ខ្យល់ដែលបក់មុនមានភ្លៀង ។ ពេលខ្ញុំបានធុំក្លិនភ្លៀង ខ្ញុំបានប្រាប់អស់លោកថាភ្លៀងជិតមកដល់ហើយ ។»

នេះជាមេរៀនមួយដែលណែនាំឲ្យចេះគិតពិចារណា តាមវិធីវិទ្យាសាស្ត្រ និងអាស្រ័យការពិនិត្យមើល ដោយសំអាងលើការពិសោធន៍ ដែលសំណាក់មុស្លីមមិនដែលស្គាល់ទេ ហើយនេះក៏ជាការស្នើសូមឲ្យលះបង់ចោលការបកស្រាយបាតុភូតដែលបានកើតឡើងជាធម្មតានោះ ដោយវិធីឧមអាម ។ អ៊ីម៉ាំអាល់-ហាឌីផ្តោតអារម្មណ៍ទៅលើ ការអភិវឌ្ឍវិស័យប្រាជ្ញារបស់សហគមន៍មុស្លីមជាពិសេស ។ យើងនឹងបិទវគ្គស្តីអំពីសកម្មភាពត្រចះត្រចង់នេះដោយលើកយកមកនូវព្រឹត្តិការណ៍ពីរ ដែលអ្នកបង្កព្រឹត្តិការណ៍នោះជាបុគ្គលរមិលគុណលើសបុគ្គលរមិលគុណទាំងឡាយ ក្នុងសម័យអ៊ីម៉ាំអាល់-ហាឌី គឺស្តេចខ៏លិហ្វត្រកូលអាប់បាស់អាល់-មូតាវ៉ាក់គីលផ្ទាល់តែម្តង ។

ថ្ងៃមួយ បុគ្គលសាហាវយង់ឃ្នងនេះធ្លាក់ខ្លួនឈឺ ។ ខណៈដែលត្រូវជម្ងឺ

អល់ឡោះហ្ជ عزّ وجلّ ។ ប្រហែលជាអ៊ីម៉ាំអាល់–ហាឌីមានបំណងបំភ្លឺការគោរពទន្ទ្រាំនិងប្រឆាំងការអះអាងមិនត្រឹមត្រូវនេះឯង បានជា ពេលព្រះអង្គទទួលផ្កាមួយទងពីកុមារម្នាក់ ព្រះអង្គបានបើបផ្កានោះហើយបានយកមកដាក់លើភ្នែកព្រះអង្គ រួចហើយព្រះអង្គមានវចនៈថា៖ «អ្នកណាបានទទួលផ្កាមួយទង បានបើបផ្កានោះ ហើយបានយកផ្កានោះមកដាក់លើភ្នែក រួចហើយថា៖ “អល់ឡ៉ហ៊ុម្ម៉ា ស្វល់លី អ៊ាឡើ មូហ៊ាំម៉ាដ្ឌ វ៉ា អាលី មូហ៊ាំម៉ាដ្ឌ” អល់ឡោះហ្ជ عزّ وجلّ នឹងចារអំពើល្អយ៉ាងច្រើនដូចគ្រាប់ខ្សាច់ទុកឲ្យអ្នកនោះ ហើយព្រះអង្គនឹងបំភ្លឺអំពើអាក្រក់ដូចនេះដែរឲ្យអ្នកនោះ ។»

កាលអ៊ីម៉ាំអាល់–ហាឌីធ្វើដំណើរទៅកាន់ស្រុកសាម៉ារ៉អ៊ុ ជាមួយភ្នាក់ងាររបស់ស្តេចខ៏លិហ្វ ឈ្មោះយ៉ាស៊ុយ៉ា ហៅស្ទើម៉ាស៊ូ ខណៈដែលមេឃស្រឡះមិនអាចនឹកស្មានបានថាអាចមានភ្លៀងឡើយនោះ អ៊ីម៉ាំបានប្រាប់ឲ្យក្បួនទូរចរត្រៀមខ្លួនព្រោះភ្លៀងជិតមកដល់ហើយ ។ ទាំងអស់គ្នាភ្ញាក់ផ្អើលខ្លាំង ។ អ្នកខ្លះព្រហើនដល់ថ្នាក់សើចឲ្យអ៊ីម៉ាំពេលព្រះអង្គប្រាប់នោះ ។ មិនយូរប៉ុន្មានពួកគេលែងសើចវិញ ទាំងអស់គ្នាភ្ញាក់ផ្អើលខ្លាំង ភ្លៀងមួយមេធំធ្លាក់ខ្លាកៗ ។ អ៊ីម៉ាំបានបែរទៅរកយ៉ាស៊ុយ៉ា ដើម្បីកម្ចាត់គំនិតមិនត្រឹមត្រូវពី



សុវត្ថិភាព ។ វិទ្យាស្ថានអាស្ហ៍លុល–បៃត៍ عليهم السلام មានមោទនភាពដែលទទួលបានការគាំទ្រពីសំណាក់បុគ្គលសមរម្យគ្រប់សម័យកាល ។

កំណត់ហេតុរបស់ទុក្ករបុរស អ៊ីបនូ អាស់–សាក់គិត (ابن السكيت) ជាសក្ខីភាពនៃការខិតខំប្រឹងប្រែងរបស់អ៊ីម៉ាំអាល់–ហាឌី صلوات الله عليه والسلام ។ អ៊ីបនូ អាស់–សាក់គិតជាអ្នកប្រាជ្ញដាច់គេមួយរូបក្នុងជំនាន់លោក ។ លោកល្បីល្បាញដោយសារសោត្រាតក្កវិជ្ជាមួយរបស់លោក ដែលអ្នកប្រវត្តិសាស្ត្រអ៊ីស្លាមល្បីៗកោតសរសើរ ។ អ៊ីបនូ អាស់–សាក់គិត ជាសាវករបស់អាស្ហ៍លុល–បៃត៍ صلوات الله عليه والسلام ។ ទេពកោសល្យរបស់លោកជាភស្តុតាងបញ្ជាក់ឲ្យឃើញនូវឥទ្ធិពលវិទ្យាសាស្ត្ររបស់វិទ្យាស្ថានអ៊ីម៉ាំអាល់–ហាឌី ។ អាស្រ័យគុណសម្បត្តិទាំងនេះឯងបានជាអាល់–មូតាវ៉ាក់គីល ជ្រើសយកអាស់–សាក់គិត ជាគ្រូរបស់កូនទាំងពីររបស់ខ្លួន ដោយគិតនេះ ជាជម្រើសល្អសម្រាប់រៀបចំការស្នងរាជ្យ ។ ថ្ងៃមួយអាល់–មូតាវ៉ាក់គីលសាកល្បង អ៊ីបនូ អាស់–សាក់គិត ចង់ដឹងថាតើលោកគាំទ្រអាស្ហ៍លុល–បៃត៍ عليهم السلام ឬទេ ។ អាល់– មូតាវ៉ាក់គីលបានសួរលោកថា៖ «តើអ្នកស្រឡាញ់អ្នកណាជាងគេ អាល់–ហាសាន់ صلوات الله عليه والسلام និងអាល់–ហ៊ូសៃន៍ صلوات الله عليه والسلام ចៅរបស់សាស្តា ឬកូនទាំង





អកុសល កូនគាត់បានស្លាប់ ចំណែកឯរូបគាត់ត្រូវបងប្អូនថ្កោលទោស ចោទប្រកាន់លោកថាឃាតករសម្លាប់កូនឯង ។ គាត់ក៏បានទៅរៀបរាប់គ្រោះអាក្រក់របស់គាត់ឲ្យអ៊ីម៉ាំអាល់-ហ្វាឌ្ទីជ្រាប ។ អ៊ីម៉ាំអាល់-ហ្វាឌ្ទីបានជួយសម្រាលទុក្ខគាត់ថាគាត់មិនបានធ្វើខុសទេ ថាគាត់បានធ្វើតាមតែកាតព្វកិច្ចរបស់គាត់ទេ ។ អ៊ីម៉ាំបានធ្វើឲ្យការវះកាត់មាននីតិសម្បទាឡើងវិញនិងគាំទ្រវិទ្យាសាស្ត្រក្នុងសម័យមួយដែល អ្នកដែលគិតថាខ្លួនអនុវត្តន៍តាមសាសនាអ៊ីស្លាម ដែលស្រង់ចំណេះចេះដឹងរបស់ខ្លួនក្រៅពីវិទ្យាស្ថានពិសិដ្ឋអាស្វលុល-បៃត៍ عليهم السلام នោះ អាចធ្វើឲ្យអភិវឌ្ឍវិស័យវិទ្យាសាស្ត្រដែលទើបនឹងកកើតនៅក្នុងសហគមន៍មុស្លីមនោះវិនាសសាបសូន្យ ។

សម័យអ៊ីម៉ាំអាល់-ហ្វាឌ្ទី ពួកតាបសក្លែងក្លាយកាន់តែសម្បូរឡើង ។ ការកាន់ច្រឡំរវាងការកាន់វត្តប្រតិបត្តិតឹងរ៉ឹង និងអាកប្បកិរិយាទ្រគោះនិងខ្វះសុជីវធម៌នោះបានលេចឡើង ។ ម្យ៉ាងទៀត បុគ្គលគ្មានចំណេះវិជ្ជាច្រើននាក់ដែលតាំងខ្លួនជាអ្នកចេះដឹងខាងសាសនា បានសាបព្រោះទ្រឹស្តីមិនត្រឹមត្រូវមួយថា សម្រស់ធម្មជាតិអាចធ្វើឲ្យមុស្លីមលំអៀងចេញពីការគោរពសក្ការៈ





ពីររបស់យើង?» ទោះជាមានសិទ្ធិនិយាយកុហកក្នុងស្ថានភាពបែបនេះក៏ដោយ អ៊ីបនូ អាស់-សាក់គិតសុខចិត្តនិយាយពិត បណ្ដាលឲ្យបុរសកំណាចទើសចិត្ត ថា៖ «សូមស្បថចំពោះអល់ឡោះហ៍ عزّ وجلّ គ្នុនប៊ូរ បម្រើរបស់អ៊ុាលី صلوات الله عليه والسلام ប៊ិន អាប៊ូ ត៏្លិប ជាទីស្រឡាញ់សម្រាប់ខ្ញុំជាងលោកនិងកូនទាំងពីរនាក់របស់លោកទៅទៀត ។» ចម្លើយនេះមិនមែនមានតម្លៃតិចជាងការគាប់បុគ្គលសាហាវយង់ឃ្នង ដូចអាល់-មូតាវ៉ាក់គីល មួយដាវចំកណ្ដាលទ្រូងនោះទេ ។ ដោយដឹងច្បាស់ថាអំពើនេះនាំមកឲ្យលោកនូវឋានសួគ៌ អ៊ីបនូ អាស់-សាក់គិតមានបំណងផ្ដល់មេរៀនតស៊ូនិងមេរៀនកិត្តិយស តាមរយៈអំពើនេះដល់មុស្លីមទាំងអស់ ។ ដូច្នេះឯងបានជាលោកមានឈ្មោះថា ទុក្ករបុគ្គលឯកដូចព្រះសាស្ដា صلى الله عليه وآله وسلم មានព្រះវចនៈថា៖ «អ្នកណានិយាយពាក្យពិតដាក់មុខបុគ្គលសាហាវយង់ឃ្នង អ្នកនោះនៅក្នុងចំណោមទុក្ករបុគ្គលឯក ។»

ទុក្ករកម្មរបស់អ៊ីបនូ អាស់-សាក់គិតមានលក្ខណៈជាទារុណកម្ម ដែលកំណត់ប្រវត្តិសាស្ត្រមិនអាចកន្លងចោលបានឡើយ ។ អាល់-មូតាវ៉ាក់គីលបានបញ្ជាឲ្យគេដកអណ្ដាតលោក ។

ការគោត់ទោសដោយវិធីព្រៃផ្សៃនេះ បញ្ជាក់ឲ្យឃើញនូវបុគ្គលិកលក្ខណៈ

របស់អាល់-មូតាវ៉ាក់គីលគឺៈ  អាល់-មូតាវ៉ាក់គីលជាបុគ្គលឃោរឃៅគុំកួនដែលមិនញញើតប្រព្រឹត្តអំពើព្រៃផ្សៃដើម្បីរម្ងាប់អារម្មណ៍ខ្លួន និងសងសឹកបទប្រមាថដែលគេបានប្រព្រឹត្តមកលើវិកលបុគ្គលិកលក្ខណៈរបស់ខ្លួនទេ ។

អាការបុគ្គលិកលក្ខណៈរបស់អាល់-មូតាវ៉ាក់គីល  ឆ្លុះបញ្ចាំងឲ្យឃើញថាបុគ្គលរូបនេះជាបុគ្គលអសទ្ធាថោកទាបដែលមិនជឿអល់ឡោះហ្ហ់ عزّ وجلّ  មិនជឿព្រះសាស្តាទាំងឡាយរបស់អល់ឡោះហ្ហ់ عزّ وجلّ ទេ ។

បន្ទាប់ពីបានស្គាល់បុគ្គលិកលក្ខណៈរបស់អាល់-មូតាវ៉ាក់គីលហើយ  គេអាចយល់បានអំពីនយោបាយទូទៅរបស់ស្តេចខ៏លិហ្វូរូបនេះ ។ រជ្ជកាលរបស់ស្តេចខ៏លិហ្វូរូបនេះជារជ្ជកាលពុករលួយទូទៅ ហើយជារជ្ជកាលួចប្លន់ស្រទាប់មនុស្សដែលខ្សត់ទ្រព្យធនជាងគេក្នុងសង្គម ។

ភ្នាក់ងាររបស់អាល់-មូតាវ៉ាក់គីល  ភាគច្រើនមានដើមកំណើតជាជនជាតិទួរគីដែលទើបនឹងបែរមកកាន់សាសនាអ៊ីស្លាម  មិនស្គាល់សាសនាខ្លួនឡើយ មិនដែលឮគេនិយាយអំពីអាស្ហ់លុល-បៃត៍ عليهم السلام  ឬគុណសម្បត្តិរបស់អាស្ហ់លុល-បៃត៍ عليهم السلام ក្នុងសាសនាឡើយ ។  អាល់-មូតាវ៉ាក់គីលបានប្រើឲ្យភ្នាក់ងារចំពួកនេះឯងនាំខ្លួនអ៊ីមុាំអាល់-ហ្ហាឌីមកកាន់ស្រុកសាម៉ារ៉អ៊ុំ ដើម្បីឃុំ



ខ្លួនព្រះអង្គឲ្យនៅតែក្នុងផ្ទះដោយមានគេឃ្លាំមើលជានិច្ច  រាំងមិនឲ្យព្រះអង្គបំពេញតួនាទីជាអ្នកអប់រំសហគមន៍មុស្លីមទេ ។  តែពន្លឺសច្ចធម៌ភ្លឺត្រចះត្រចង់មិនមានអ្វីអាចហាមឃាត់  មិនឲ្យទៅដល់បេះដូងបរិសុទ្ធបានឡើយ ។ មិនមានតែ  អ៊ីបនូ  អាស់-សាក់គិត  ម្នាក់ទេដែលបានទទួលនូវគុណបុណ្យនេះ ។

## សកម្មភាពត្រចះត្រចង់ក្នុងប្រវត្តិសាស្ត្រ

ជីវប្រវត្តិរបស់អ៊ីមុាំអាល់-ហ្ហាឌីពិបាកថ្លែងរៀបរាប់បន្តិច  អាស្រ័យមូលហេតុដែលយើងបានលើកឡើងរួចមកហើយ ។ ក៏ប៉ុន្តែសកម្មភាពត្រចះត្រចង់ដែលបានកើតមានមកពីទំនាក់ទំនង រវាងបុគ្គលិកលក្ខណៈឧត្តុង្គឧត្តមរបស់ព្រះអង្គនិងបុគ្គលជំនិតមួយចំនួនតូច ក្នុងសម័យព្រះអង្គនោះអាចផ្តល់ផលប្រយោជន៍ដល់យើងបានដើម្បីបំពេញចន្លោះទំនេរនេះ ។  តទៅនេះយើងនឹងលើកឡើងនូវសកម្មភាពត្រចះត្រចង់ខ្លះមកអធិប្បាយ ។

សម័យអ៊ីមុាំអាល់-ហ្ហាឌីគេមិនសូវស្គាល់ការវះកាត់ទេ ។ បុរសមុស្លីមម្នាក់មានកូនប្រុសម្នាក់មានជម្ងឺតម្រងទឹកនោម ។  គ្រូពេទ្យបានដាក់បញ្ញត្តិឲ្យវះកាត់ ។ បុរសរូបនេះ ជាមុស្លីមស្មោះត្រង់ ព្រមប្រថុយវះកាត់កូនគាត់ ។ តែ